# ស៊ីសុវត្ថិ-សិរិមតៈ
# មនុស្សនៅពីក្រោយខ្នងលន់-នល់

## L'Homme fort du 18 mars 1970

ដោយ សុទ្ធ-ប៉ូលិន ⋆ ថ្ងៃទី១២ មិថុនា ២០០៦

លោកលន់-នល់ច្បាស់ជាមិនហ៊ានលើកកូនម្រាមដៃមួយផងទេ ទៅលើស្តេចសីហនុ ប្រសិនបើពុំមានការប្តេជ្ញាចិត្តដ៏មោះមុតរបស់ជនទី២ ឬភូឈ្មួយរបស់លោក, អ្នកអម្ចាស់ស៊ីសុវត្ថិ-សិរិមត: ។

ទ្រង់សិរិនត:មានការភ័យខ្លាចត្រូវបង់ខាតជីវិតខ្លួនឯងនិងរលាយរលត់ ដល់ក្រុមគ្រួសាររបស់លោក នៅក្នុងជម្លោះជាមួយព្រះប្រមុខរដ្ឋនេះ ។ ពាក្យចចាមអារាមដ៏សន្ធឹកសន្ធាប់ ដែលរសាត់មកពីក្រុងប៉ារីស បានផ្តល់ពត៌មានថា ស្តេចសីហនុនឹងធ្វើការកំចាត់កំចាយជាដំបូងបំផុត គឺទៅលើទ្រង់សិរិមត: ហើយនិងក្រុមបក្សពួករបស់ទ្រង់នោះឯង ។ ដោយភ័យស្លុតស្លន់ (ខ្លាចដាច់ក្បាល) ទ្រង់សិរិមត:ក៏ចាប់ផ្តើមមានកំហឹងចំពោះលោកលន់-នល់ ដែលមិនដឹងជាមាននយោបាយរេទៅខាងណា ហើយដែលសេចក្តីរួញរាមិនសំរេចចិត្ត បានបណ្តាលឲ្យពួកអ្នកតំណាងរាស្ត្រមានការផ្លាស់ប្តូរមនោសញ្ចេតនា នៅពេលចុងក្រោយនេះវិញ ជាពិសេសគឺលោកដាញ់-សាង ។ ពួកអ្នកទាំងនេះ ស្រាប់តែមានភក្តីភាពស្មោះសរ ជាមួយនឹងសម្តេចសីហនុឡើងវិញ… ដែលជាសេចក្តីបញ្ជាក់បង្ហាញយ៉ាងគួរឲ្យអស់សង្ស័យថា ពួកអ្នកតំណាងរាស្ត្រខ្មែរក្នុងសម័យនោះ មានសេចក្តីជាប់ចិត្តយ៉ាងស្អិតគ្មានរបេះជាមួយនឹងស្តេចសីហនុ បើទោះជាព្រះអង្គមាននយោបាយលក់ទឹកដីឲ្យយៀកកុងយ៉ាងណាក៏ដោយ (អ្នកខ្លះនិយាយថា ព្រះអង្គចង់លក់ដីឲ្យនរណាលក់ទៅ… ដីនេះជាដីរបស់ទ្រង់ស្រាប់) ។

អ្នកអង្គម្ចាស់ស៊ីសុវត្ថិ-សិរិមត:មិនបានដឹងអំពីការត្រូវរ៉ូវគ្នាដ៏សម្ងាត់ ដែលទ្រង់យល់ថាបានប្រព្រឹត្តឡើង រវាងលោកលន់-នល់ហើយនិងសម្តេចសីហនុ, ហើយនិងរឿងអ្វីខ្លះៗ ដែលអ្នកទាំងពីរបាននិយាយគ្នានោះទេ កាលដែលព្រះអគ្គមគ្គទ្ទេសក៍ ហើយនិងលោករដ្ឋមន្ត្រីទី១បានជួបជុំគ្នានៅទីក្រុងប៉ារីស ។ បាតុកម្មប្រជាពលរដ្ឋប្រឆាំងនឹងយួននេះ មិនមែនជាស្នាដៃរបស់ទ្រង់ទាល់តែសោះ ។ ម៉្យាងវិញ

ទៀតសិរិមតៈដឹងថា លន់-នល់ស្ថិតនៅក្នុងស្ថានភាពមួយ ដែលអាចបះក្រឡាប់ ឬអាចវេទាំងសង្ខាង គឺថាលោកមានលទ្ធភាព«វិល» ទៅខាងរដ្ឋាភិបាលផង ឬក៏វិល ទៅខាងសម្ដេចសីហនុផង ។ ហេតុដូច្នេះហើយ បានជាទៅថ្ងៃមុខទៅ ទ្រង់សិរិមតៈ មិនសូវមានការចុះសំរុងជាមួយនឹងពួកបញ្ញាជន និងក្រុមពួកនិស្សិតទេ សឹងតែពេករយៈកាលនៃសាធារណរដ្ឋខ្មែរ ។ នៅចំពោះមុខការស្មុះដោលកញ្ជ្រោលនៃព្រឹត្តិ-ការណ៍ ហើយនិងសេចក្ដីស្លូតស្លាប់របស់ឧត្ដមសេនិយ៍លន់-នល់ ដែលទ្រង់ចាប់ផ្ដើមបាត់បង់ការទុកចិត្តនិងការសង្ស័យ ថាមានល្បិចកលដ៏ជ្រាលជ្រៅ ព្រមទាំងនៅក្រោមឥទ្ធិពលនៃសេចក្ដីតក់ស្លុត ទ្រង់សិរិមតៈបានកំហែងគំរាមដណ្ដើមយកអំណាចដោយត្រង់ៗតែម្ដង ។ ចំពោះសិរិមតៈ, បើលន់-នល់មានអាកប្បកិរិយាហ្នឹងថ្កល់ ឥតឃ្លេងឃ្លោង... នៅក្នុងកាលៈទេសៈនៃខ្យល់ព្យុះនយោបាយបែបនេះ គឺមកពីលោកឧត្ដមសេនិយ៍ មានទំនុកចិត្តរបស់ព្រះប្រមុខរដ្ឋ ។ ម្ល៉ោះហើយទ្រង់សិរិមតៈ មានទំនាស់ហប្ញទ័យជាយ៉ាងខ្លាំង នឹងការប្រែប្រួលគោលជំហររបស់ក្រុមអ្នកតំ-ណាងរាស្ត្រ ដែលជាបក្សពួកនយោបាយរបស់ទ្រង់, ក្រុមមួយដែលអាចក្បត់ ឬអាចបោះបង់ទ្រង់ចោលវិញ បន្ទាប់បីមានការប្រើកម្លាំងកំហែងកំហល់ ពីសំណាក់អ៊ុមម៉ាណូរិនកាលពីថ្ងៃម្សិល, ថ្ងៃទី១៦មីនា១៩៧០ ។

នៅក្នុងឱកាសរួមប្រជុំមួយនៃពួកមុខមន្ត្រីសំខាន់ៗនៃព្រះរាជាណាចក្រ នៅយប់ថ្ងៃទី១៧មីនា១៩៧០ នៅផ្ទះលោកលន់-នល់, ការរួមប្រជុំដែលបន្តរហូតដល់ម៉ោង៤ភ្លឺនៃថ្ងៃទី១៨, ទ្រង់សិរិមតៈដែលអមដោយមនុស្សខ្លាំងនៅក្នុងរដ្ឋាភិបាទ្រង់មានជាអាទិ ឧប-គឹមអាន និងទ្រិញ-វ៉ាញ, បានកំហែងឧត្ដមសេនីយ៍លន់-នល់ឲ្យទម្លាក់ស្ដេចសីហនុ, បើពុំនោះសោតទេ ឲ្យដើរចុះចេញខ្លួនឯង (រឿងនេះ គឺលោកហង្សធុនហាក់ជាអ្នកនិយាយប្រាប់លោកលន់-ណុន) ។

ទាំងនេះជាសំដីមុតដូចមុខកាំបិត ដែលទ្រង់សិរិមតៈបាននិយាយទៅកាន់លោកលន់-នល់ នៅក្នុងឱកាសរាត្រីខ្យល់ព្យុះកំបុតត្បូងនោះ ៖

- បើលន់ឯងមិនទម្លាក់សីហនុទេ... ខ្ញុំនឹងចាប់នល់ឯងដាក់គុក...

នៅក្នុងចំណោមឥស្សរជនទាំងបីនាក់ ៖ សីហនុ, លន់-នល់ និងសិរិមតៈ, គឺជនក្រោយនេះដែលមានអត្តចារឹកត្រង់ជាងគេបំផុត, និយាយចំៗកំបុតកំបុយ, គ្មានល្បិចកល, គ្មានអំពើលាក់លៀម ។ ប៉ុន្តែបើលន់-នល់មានលក្ខណៈជាអ្នកជាតិនិយមដ៏ជ្រាលជ្រៅ, សីហនុបានលេចឡើងជាជនប្រាស់ចាកសីលធម៌, ពោរពេញដោយអំពើពុតត្បុត, ភូតភរ, គេចវេះ, កាចសាហាវយង់ឃ្នង និងប៉ិនប្រសប់ខាងបង្វិលសភាពការណ៍ជាងគេទាំងអស់ ។ នៅពេលនោះ (យប់ថ្ងៃទី១៧មីនា១៩៧០) ប្រសិនណាបើទ្រង់សិរិមតៈបានសង្ស័យជាមុនតែបន្តិចបន្តួច ថាសីហនុកំពុងតែឈោងទៅដល់គោលប្រាថ្នាចុងចប់របស់ទ្រង់រួចទៅហើយ តាមដងមាគ៌ាដ៏មហាបត់បែនរបស់ទ្រង់... គឺហក់លោតទៅចូលយៀកកុង ដើម្បីរុញច្រានកម្ពុជា ឲ្យរមៀលចូល

ទៅក្នុងភ្លើងសង្គ្រាម ដោយព្រះអង្គជាអ្នកមានប្រៀប, ក្នុងប្រការទាញផលចំណេញសំរាប់ខ្លួនឯងនិងសំរាប់ប្រពន្ធ... នោះច្បាស់ជាទ្រង់សិរិមតៈ មិនបានបង្ខំឲ្យលន់-នល់ទម្លាក់សីហនុទេ... ពីព្រោះជាទង្វើដែលណែនាំឲ្យជនក្រោយនេះ បានសំរេចតាមការប៉ងប្រាថ្នាទៅវិញតែប៉ុណ្ណោះ ។ បើពុំនោះសោតទេ ទ្រង់នឹងរង់ចាំឱកាសមួយផ្សេងទៀតដែលល្អជាងនេះ ។ គឺហេតុដូចនេះហើយ បានជាក្នុងរយៈពេល៣ឆ្នាំក្រោយមក, នៅក្នុងឆ្នាំ១៩៧៣, ស៊ីសុវត្ថិ-សិរិមតៈនៅតែមានអាការៈក្តៅក្រហាយនឹងសីហនុមិនទាន់បាត់... ហាក់ដូចជាមនុស្សម្នាក់ដែលចាញ់បោកគេ អស់ផ្លូវដោះស្រាយ (គឺចាញ់កលគេបណ្តាលឲ្យប្រទេសជាតិធ្លាក់ចូលក្នុងសង្គ្រាម) ដោយបានផ្ញើលិខិតចំហមួយ ទៅស្តីបន្ទោសសីហនុ (ថ្ងៃ២៧សីហា១៩៧៣) ដែលមានសេចក្តីដកស្រង់ដូចតទៅនេះ ៖

«ទោះជាយ៉ាងនេះក៏ដោយ, ទ្រង់ប្អូនបានចិញ្ចឹមជាសម្ងាត់ នូវចំណងមេត្រីជិតស្និទ្ធ ជាមួយនិងយៀកណាមខាងជើង និងពួកយៀកកុង, ចំណងមេត្រីដែលអនុ-ញ្ញាតឲ្យពួកនេះ មកតាំងទីជម្រកដ៏សំបើមនៅក្នុងទឹកដីរបស់យើង ដោយរាប់ទាំងមន្ទីរពេទ្យ, មជ្ឈមណ្ឌលហ្វឹកហ្វឺន, មូលដ្ឋានបង្កប់គ្រឿងអាវុធ... មជ្ឈមណ្ឌលសំរាកយកកម្លាំង ដែលពីទីនោះទៅ មានកិច្ចប្រតិបត្តិការវាយប្រហារទៅលើវៀតណាមខាងត្បូង ។ ទីតាំងជម្រកទាំងនេះ ឋិតនៅតាមជួរបណ្តោយព្រំប្រទល់ខាងកើតរបស់យើង តាំងពីរតនគិរីចុះរហូតទៅដល់សមុទ្រ ។ ទ្រង់ប្អូនអាចធ្វើសេចក្តីបញ្ចប់ដោយខ្លួនឯងទៅចុះ ថានយោបាយបែបនេះ បានលុបចោលដោយគ្មានពេលវិលត្រឡប់នូវអព្យាក្រឹត្យភាព ដែលបានចែងនៅក្នុងរដ្ឋធម្មនុញ្ញ... ដើម្បីរុញច្រានពួកយើងទាំងអស់គ្នា ឲ្យធ្លាក់ចូលក្នុងភ្លើងសង្គ្រាមបច្ចុប្បន្ន, សង្គ្រាមមួយដែលប្រជាជាតិយើងតែងតែបានប្រឹងប្រែងចៀសវាងដោយប្រើគ្រប់មធ្យោបាយ» ។

«ដោយត្រូវប្រយុទ្ធជាមួយនឹងប្រជាជននៅក្នុងតំបន់ ដែលពួកគេបានកាន់កាប់ខុសច្បាប់ ដែលមានទ្រង់ប្អូនតែម្នាក់ប៉ុណ្ណោះបានអនុញ្ញាត, ហើយដែលត្រូវទទួលថ្កោលទោស ដោយរដ្ឋាភិបាលខ្មែរពេញច្បាប់, ពួកយៀកណាមខាងជើងនិងពួកយៀកកុងគ្មានបានរកឃើញច្រកផ្លូវអ្វីដ៏ល្អប្រសើរ ក្រៅអំពីការវាយប្រហារដោយចំហ, ការវាយប្រហារមួយ ដែលពួកគេចង់បានឲ្យឆាប់រហ័ស ប្រកបដោយលក្ខណៈផ្តាច់ព្រ័ត្រ តាមសំណូមពររបស់ទ្រង់ប្អូន ដែលបានធ្វើនៅទីក្រុងកង់តុង ខែមេសា ១៩៧០» ។

★★★ ទាំងនេះជាពាក្យសំដីក្តៅក្រហាយនិងសោកស្តាយដ៏ឥតប្រយោជន៍រប-ស់ទ្រង់សិរិមតៈ តទល់នឹងស្តេចសីហនុ ហើយតទល់នឹងការបោកបញ្ឆោតរបស់ក្រុមបក្សពួកកុម្មុយនិស្តពិភពលោក ។ ពីព្រោះថាអ្វីៗបានក្លាយទៅជាផេះអស់ទៅហើយ ។ អ្វីៗក៏បានរសាត់តាមខ្យល់អស់រលីងទៅហើយ... Gone with the wind ។ បើទោះជាមានការប្តឹងប្តល់ដល់ទេវតា ក៏ប្រវត្តិសាស្ត្រមិនបកត្រឡប់វិលវិញដែរ !

❑

❑ ❑

ស្រាប់តែថ្ងៃ១៨មីនា១៩៧០, ថ្ងៃវាសនាកម្មនៃការទម្លាក់ស្ដេចសីហនុបានរសាត់មកដល់ ដោយលបៗ, ដោយភ័យខ្លាច, ដោយរារែកក្នុងចិត្ត ដូចតែបុគ្គលិកលក្ខណៈរបស់ឧត្ដមសេនីយ៍លន់-នល់ខ្លួនឯង ។ គឺវាហាក់ដូចជាថា អន្ទាក់ព្រហ្មលិខិតវាធ្លាក់គ្របជាប់ទៅលើស្ដេចសីហនុតែម្ដង... ឬពុំដូច្នោះទេ គឺលន់-នល់ដែលរមៀលចូលខ្លួនឯងទៅក្នុងអន្ទាក់របស់បិសាច ?? គឺពីព្រោះតាំងពីថ្ងៃនោះមក កម្មអពមង្គលទាំងប៉ុន្មាន បានតាមវាយប្រហារជនទាំងពីរដោយគ្មានសំចៃដៃ (បីបួនថ្ងៃក្រោយមកប៉ុណ្ណោះ, បងប្រុសបង្កើតរបស់លោកលន់-នល់, ឈ្មោះហ៊ិន-និល បានត្រូវពួកភ្នាក់ងារយៀកមិញវះពោះស៊ីថ្លើមនៅចំការកៅស៊ូជប់) ។

តើមានរឿងអ្វីខ្លះកើតឡើងនៅថ្ងៃនោះ ? តើលន់-នល់បានសំរេចចិត្តធ្វើរដ្ឋប្រហារមួយដោយឥតព្រៀងទុក ? ទម្លាក់ស្ដេចមួយដែលមានប្រជាប្រិយភាព ដែលចុះមកពីអំបូរទេវរាជ ដោយគ្មានរៀបចំជាមុន គ្មានការលោភលន់ផ្ទាល់ខ្លួនទាល់តែសោះ ដោយគ្មានបានរៀបចំគ្រោងការណ៍ដឹកនាំរដ្ឋបន្តិចបន្តួច ក្រៅតែពីការតស៊ូប្រឆាំងយួន... ពោលដោយគ្មានគំនិតអ្វីទាំងអស់ ?? តាមពិតលន់-នល់ មិនដែលមានឯករាជ្យខាងផ្លូវគំនិតសំរាប់គ្រប់គ្រងប្រទេសជាតិទាំងមូលនោះទេ, អ្វីៗដែលគាត់បានធ្វើ គឺធ្វើឡើងតាមបញ្ជារបស់ព្រះមហាក្សត្ររបស់គាត់ ។ គឺហេតុដូចនេះហើយបានជាសីហនុតែងតែទុកលន់-នល់នៅក្បែរខ្លួនជានិច្ច ។ កាលណាឥតមានវត្តមានឬឥតបញ្ជាពីចៅហ្វាយទេ លោកលន់-នល់ឥតដឹងធ្វើអ្វី ឥតសំរេចអ្វីបានទាំងអស់។ ហើយរឿងនេះ ស្ដេចសីហនុដឹងច្បាស់លាស់ណាស់ ។ បុគ្គលិកលក្ខណៈរបស់លោកលន់-នល់ជាមនុស្សខ្លាំង, ជា«ស៊ូហារតូខ្មែរ» គឺគ្រាន់តែជា«រឿងព្រេងនិទាន» ដែលស្ដេចសីហនុបានរៀបរៀងតែប៉ុណ្ណោះ ។ ទោះជាយ៉ាងណាក្ដី លោកលន់-នល់មិនដែលស្រវឹងនឹងខ្លួនឯងទេ ។ គាត់មិនដែលបានទទួលយកតំណែងជាអាជ្ញាកណ្ដាល ដែលជំរុញឲ្យគាត់កាត់ទោសមហាក្សត្រខ្លួនឯង ដោយសប្បាយចិត្តនោះទេ ។ តាត្រសក់ផ្អែមនៅតែជាអ្នកយាមរាជវាំងនៃទីក្រុងអង្គរ... ចំណែកលន់-នល់នៅតែជាអ្នកយាមរាជវាំងនៃទីក្រុងភ្នំពេញ ។ គាត់មិនបានក្លាយទៅជាស្ដេចកនឬក៏ជាអ្នកតាជំបងក្រញូងសោះឡើយ (ក្នុងរឿង«បក្សីចាំក្រុង»...តាជំបងក្រញូងឡើងធ្វើស្ដេចខ្លួនឯង ដោយបង្ក្រាបអ្នកដទៃរាបដូចស្មៅ) ។

ពេលនេះជាលើកទី១ហើយ ដែលលន់-នល់ត្រូវសំរេចរឿងសំខាន់មួយដោយខ្លួនគាត់ ។ តាមការសង្កេតរបស់ខ្ញុំផ្ទាល់, ចាប់តាំងពីថ្ងៃ«១៨មីនា១៩៧០»នោះមក លន់-នល់ក្នុងនាមជាបុគ្គល ក៏មានលំនាំដូចរឿង «ទឹករលក» របស់ Spinoza «ដែលត្រូវបោកបក់ដោយខ្យល់ពីរច្រាស់ទិសគ្នា, មិនដឹងជារេទៅខាងណាមកណា, មិនដឹងជានៅឯណាជោគជតារបស់ខ្លួននោះទេ» ។ នៅពេលនោះ លន់-នល់កំពុងតែរេ

នៅចន្លោះឆន្ទៈពីរដែលបោកប្រាស់ទិសគ្នា, គឺរវាងឆន្ទៈសីហនុ ហើយនិងឆន្ទៈរបស់សិរិមតៈ ។

លោកមិនដឹងថា តើត្រូវយកនរណាទៅជំនួសសីហនុទេ ពីព្រោះលោកមិនចង់ជំនួសស្តេចដោយខ្លួនឯង ។ នៅថ្ងៃ១៨មីនា គ្មាននរណាឃើញលោកលន់-នល់ទាល់តែសោះ ។ លោកធ្វើចំណាត់ការ តាមរយៈមនុស្សផ្សេងៗទាំងអស់ ។ លោកនៅជាប់ជំពាក់ជំពិននឹងមន្តស្នេហ៍របស់ស្តេចសីហនុនៅឡើយ ។ គឺហាក់ដូចជាលោកមិនចង់សម្លាប់បង្កើយសត្វពស់ ។ លោកធ្វើអ្វីៗទាំងអស់ ទំនងដូចជាមានគេទាញខ្សែពីចម្ងាយ ឬរុញច្រានពីក្រោយ ។ គឺហេតុដូច្នេះហើយបានជា នៅបន្ទាប់ពីថ្ងៃ១៨មីនា១៩៧០, ពាក្យចចាមអារាមមាត់ចាបមាត់ព្រាបដែលគេទប់មិនឈ្នះ បានត្រូវផ្សព្វផ្សាយគ្រប់ច្រកល្ហកពាសពេញរាជធានី, ហើយដែលនិយាយថា សីហនុហើយនិងលន់-នល់ត្រូវរ៉ូវគ្នា, ហើយថាលន់-នល់គ្រាន់តែចង់ជួយស្រោចស្រង់មរតករបស់សីហនុ ដែលជាស្នាដៃរបស់គាត់ផងដែរតែប៉ុណ្ណោះ ។ ប្រហែលជាលោកឧត្តមសេនីយ៍ខ្មែរចង់បង្ហាញថា លោកបានធ្វើ«បដិវត្តន៍មួយដែលគ្មានការបង្ហូរឈាម?» ។ ប្រសិនបើពិតជាដូច្នោះមែន លោកមានកំហុសធ្ងន់ហើយ ដូចពាក្យភាសិតខ្មែរដែលនិយាយថា ៖ «ចិត្តមិនដាច់ ធ្វើស្តេចមិនបាន» ។ ម្ល៉ោះហើយនៅថ្ងៃនោះ លន់-នល់ក៏បណ្តាលឲ្យមាន«រដ្ឋប្រហារស្របច្បាប់» ដែលជាទង្វើទាំងស្រុងរបស់អ្នកអម្ចាស់ស៊ីសុវត្ថិ-សិរិមតៈ ។ គេក៏បណ្តោយឲ្យមានការបំផ្លាញកេរ្តិ៍ឈ្មោះរបស់សម្តេចសីហនុ នៅវេទិការបស់រដ្ឋសភាជាតិ តាមរយៈមនុស្សបន្ទាប់បន្សំដូចជាអ៊ិន-តាំ, ទ្រិញ-វ៉ាញ, ហឿ-ឡាយអ៊ិន ។ ធ្វើមើលតែការជេរប្រទេចផ្តាសារនេះ ដែលគួរឲ្យចង់សើចទាំងអស់... អាចមានកម្លាំងគ្រប់គ្រាន់ ដើម្បីដកពិសជនផ្តាច់ការម្នាក់ ដែលមានទេពកោសល្យដូចស្តេចសីហនុ ? ។ គឺទំនងហាក់ដូចជាថា ពួកមេៗផ្តួងផ្តើមរដ្ឋប្រហារទាំងប៉ុន្មាននៃថ្ងៃ១៨មិនា១៩៧០ ៖ លន់-នល់, សិរិមតៈ, ស៊ឹម-វ៉ារ មិនចង់ប្រឡាក់ដៃខ្លួនឯង ។ ម្ល៉ោះហើយគេអាចមើលឃើញច្បាស់ណាស់ថា រដ្ឋប្រហារនេះជារដ្ឋប្រហារធ្វើឡើងដោយចៃដន្យ ហើយដែលពួកមេដឹកនាំ ដែលគេចោទថាជា «អ្នកផ្តួងផ្តើម» មិនបានគ្រោងរៀបចំទុក ។ យ៉ាងច្រើនណាស់គ្រាន់តែជាកំហឹងក្រេវក្រោធមួយរយៈពេលនៃប្រជាជាតិខ្មែរសម័យនោះ ដែលងើបឡើងបះបោរប្រឆាំងនឹងការផិតក្បត់របស់ព្រះអគ្គមគ្គទ្វេសក៍របស់ខ្លួន ។ ទោះជាយ៉ាងនេះក៏ដោយលន់-នល់ប្រហែលជាអាចធ្វើឲ្យរដ្ឋប្រហារនេះ បានសំរេចជោគជ័យ ប្រសិនបើលោកមានដៃដែក និងការប្តេជ្ញាចិត្តគ្មានរង្គោះរង្គើដូចស្តេចកន ។ នៅពេលនោះលោកមានប្រជាពលរដ្ឋខ្មែរទាំងមូលនៅពីក្រោយខ្នងលោកទៅហើយ ។

លន់-នល់គ្រាន់តែសំរេចឲ្យបិទអាកាសយានដ្ឋាន បិទទ្វារស្រុកខ្មែរបណ្តោះអាសន្ន មិនឲ្យក្រុមអ្នកកាសែតបរទេសចេញចូល ឲ្យពួកយោធាបើកបររថក្រោះតាមផ្លូវទីក្រុងភ្នំពេញនៅម៉ោង៤ភ្លឺ ដែលជាការសំដែងយុទ្ធសិល្បមួយ ដើម្បីឲ្យអ្នកស្រុ

កភ័យខ្លាច ហើយដែលជាលេសឲ្យពិភពលោកចោទគាត់ថា ជាអ្នកធ្វើរដ្ឋប្រហារបណ្តោយទៅ ។ តាមពិតលោកលន់-នល់ ចង់យកគំរូតាមលោកឧត្តមសេនីយ៍ដឺគ្លោល នៅពេលដែលប្រមុខរដ្ឋបារាំងម្នាក់នេះ វិលត្រឡប់មកពីស្រុកអាល្លឺម៉ាញ បន្ទាប់ពីមានព្រឹត្តិការណ៍បះបោរនៃពួកក្រុមយុវជនបារាំង នៅខែឧសភាឆ្នាំ១៩៦៨ ។ កាលណោះដើម្បីសំរន់សតិអារម្មណ៍លោកប្រមុខរដ្ឋបារាំង... បានធ្វើការសំដែងមួយដែលមានលំនាំហាក់ដូចជារដ្ឋប្រហារ គឺលោកបញ្ជាឲ្យពួកយោធាបើករថក្រោះ តាមផ្លូវទីក្រុងប៉ារីសពេញមួយរាត្រី ។ ក្នុងប្រការនេះ នៅក្នុងគំនិតដំបូងរបស់លន់-នល់ គឺគាត់ចង់ធ្វើតាមឧត្តមសេនីយ៍ដឺគ្លោល មិនមែនចង់ធ្វើតាមឧត្តមសេនីយ៍ស៊ូហារតូនោះទេ ។ លន់-នល់គាត់គ្មានអ្វីត្រូវបុកប្រឆាំងជាមួយនឹងស្តេចរបស់គាត់ទេ ផ្ទុយទៅវិញគាត់គ្រាន់តែបានដើរតួរជាឧបករណ៍ បើកផ្លូវឲ្យព្រះប្រមុខរដ្ឋរបស់គាត់រត់ទៅចូលពួកខាងរដ្ឋកុម្មុយនិស្តបានដោយស្រួលតែប៉ុណ្ណោះ ដោយចង់បង្កើតឲ្យមានបដិវត្តន៍មួយ ដែលឥតមានការបង្ហូរឈាម ។ ក្នុងករណីនេះ «បដិវត្តន៍»របស់គាត់គឺជាសុបិន្តរវើរវាយសុទ្ធសាធ ដែលនាំទៅរកលទ្ធផលដ៏សែនល្វីងជូរចត់ ។ ក៏ដូចលោកម៉ៅ-សេទុងបានបញ្ជាក់រួចមកហើយ «ការដឹកនាំបដិវត្តន៍មួយ មិនមែនដូចការរៀបចំរាត្រីសមោសរនោះទេ» ។ គឺបានសេចក្តីថា លោកលន់-នល់បានធ្វើចំណាត់ការរាក់ៗសើរៗ ហាក់ដូចជារឿងកំប្លែងសើចលេង គឺវាមិនសមស្របនឹងលក្ខណៈធ្ងន់ធ្ងរនៃស្ថានការណ៍សម័យនោះ ដែលវិលក្រឡាប់ដូចទឹកនៅលើស្លឹកឈូក ។ អ្នកកាន់ព្រះពុទ្ធសាសនាលន់-នល់ស្វែងរកឧត្តមគតិសន្តិនិយម ហើយមានជំនឿទៅលើសេចក្តីសុទ្ធចិត្តរបស់ខ្មាំងសត្រូវ (ស្តេចសីហនុ) ។ គាត់ពុំមានសភាវៈរបស់ឧត្តមសេនីយ៍ស៊ូហារតូ ដែលជនក្រោយនេះមិនដែលមានជំនឿទេ ថាមាន «ទេព្តាចុះមកជួយ»... ឬក៏ថា«ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់» ។

ដោយមានកិច្ចការងារច្រើនពេកនៅកាសែត«នគរធំ» ខ្ញុំមិនបានដឹងសោះអំពីសភាពការណ៍ធ្ងន់ធ្ងរ ដែលកើតមានលើងបន្ទាប់ពីការវាយប្រហាររបស់អ៊ុម-ម៉ាណូរិននៅថ្ងៃទី១៦ ។ ប៉ុន្តែមានគេមកប្រាប់ខ្ញុំនៅល្ងាចថ្ងៃទី១៨ ថារឿងស្តេចសីហនុ «ត្រូវចប់ត្រឹមនេះហើយ» ។

នៅពេលក្រោយមក ខ្ញុំដឹងថានៅថ្ងៃនោះ ថ្ងៃទី១៨មីនា១៩៧០, សុស្តែន-ហ្វែរណង់ដែស, រដ្ឋមន្ត្រីក្រសួងប៉ូលិសរបស់ស្តេចសីហនុ កំពុងបានចាប់មិត្តភក្តិរបស់ខ្ញុំឈ្មោះ ថោង-លឹមហួង, អ្នកសារពត៌មានម្នាក់ ដែលបំរើនៅក្នុងផ្ទះលោកឧត្តមសេនីយ៍លន់-នល់ ។

❑

❑ ❑

នៅព្រឹកថ្ងៃទី១៩មីនា, ដោយស្តាប់ការផ្សាយរបស់វិទ្យុជាតិ ខ្ញុំមានការភ្ញាក់ស្រឡាំងកាំង នឹងសម្លេងស្មើ និងមួយៗរបស់លោកលន់-នល់ ដែលផ្សាយបញ្ជាក់អំពី

សេចក្តីសំរេចរបស់សភាទាំងពីរ ដែលរួមប្រជុំគ្នាអង្គសមាជ ដើម្បីទម្លាក់សម្តេចសីហនុព្រះប្រមុខរដ្ឋ... ហើយលោកឧត្តមសេនីយ៍ក៏ប្រកាសអំពាវនាវឲ្យប្រជាជនស្ថិតនៅក្នុងសភាពស្ងប់ស្ងៀម ។ បន្ទាប់មកក៏មានការពិភាក្សាទ្រហឹងអឺងអាប់នៅក្នុងរដ្ឋសភា ។ ដោយពាក្យសំដីហឹង្សាក្រៃលែង លោកទ្រិញ-វ៉ាញ, អ៊ិន-តាំ, ហឿ-ឡាយអ៊ិន, ដាញ់-សាង, អ៊ូ-ឯក ។ល។ បានឡើងមកកាន់វេទិកាម្នាក់ម្តងៗ ដើម្បីចោទប្រកាន់អំពើពុករលួយ, អំណាចផ្តាច់ការ និងការក្បត់ជាតិរបស់សម្តេចសីហនុ ដែលមានរយ:ពេលវេលាជាង១០ឆ្នាំមកហើយ ។«គឺដល់ពេលមួយដែលយើងត្រូវរំដោះខ្លួនពីនឹមសក្តិភូមិរបស់នរោត្តម-សីហនុ», នេះជាសំដីរបស់លោកទ្រិញ-វ៉ាញ ។ គឺជាលើកទី១ហើយ ដែលខ្ញុំបានឮពួកអ្នកតំណាងរាស្ត្រហៅសីហនុ ដោយគ្មានពាក្យគួរសមថា «សម្តេច» នៅពីមុខ ។

ចំណែកឪពុកធំរបស់ខ្ញុំវិញ, លោកស៊ឹម-វ៉ារ បាននិយាយពាក្យកំប្លែងលេង ដែលមិនសមស្របនឹងកាល:ទេស:ពេលនោះសោះ ដែលតម្រូវឲ្យអ្នកផងមានទឹកមុខស្រពាប់ស្រពោន របស់ជនហែរខ្មោចរបស់ព្រះបិតា... ប៉ុន្តែក៏គឺដើម្បីសងសឹកដល់ពួកអ្នកទាំងអស់គ្នានៅក្នុងសភាទាំងនេះដែរ ដែលធ្លាប់បានដកអភ័យឯកសិទ្ធិរបស់គាត់ តាមបញ្ជារបស់សម្តេចសីហនុ ដោយនិយាយថា ៖ «កាលពីដើម កាលខ្ញុំស្រែកថាមានឆ្កែព្រៃ, កាលណាខ្ញុំតិទៀនសម្តេចសីហនុ គឺខ្ញុំធ្វើតែម្នាក់ឯងគត់ ។ ដល់មកពេលឥឡូវ ដែលមនុស្សគ្រប់គ្នាចោមរោមថ្កោលទោសសម្តេចសីហនុដូច្នេះ... ខ្ញុំមិនចូលដៃជាមួយពួកគេទេ ។ ខ្ញុំនឹងដើរតួជាមេធាវីការពារទ្រង់វិញម្តង...» ។

នៅពេលក្រោយមក លោកអ៊ុំស៊ឹម-វ៉ារបានប្រាប់ខ្ញុំថា មានតែតំណាងរាស្ត្រ២នាក់ប៉ុណ្ណោះទេ ដែលបានបោះឆ្នោតអនុប្បវាទមិនព្រមទម្លាក់ស្តេចសីហនុ កាលពីកិច្ចរួមប្រជុំជាប្រវត្តិសាស្ត្រនោះ គឺលោកគីម-ផុន និងសុះ-សាអុន, ប៉ុន្តែដើម្បីជាទង្វើសមស្របនឹងបរិយាកាសរួបរួមជាតិនៅពេលនោះ គណ:កម្មាធិការនៃសភាទាំងពីរ ក៏បានសំរេចជ្រើសរើសយកការបោះឆ្នោតជាឯកច្ឆន្ទ ពោលគឺមានសម្លេង១០០ភាគរយ (ទម្លាក់ស្តេចសីហនុ) ។ ជាសំណើចចំអកនៃព្រហ្មលិខិត, ៤-៥ថ្ងៃក្រោយមក គឺអ្នកតំណាងរាស្ត្រទាំង២នេះឯង, គីម-ផុន និង សុះ-សាអុន ដែលបានត្រូវបក្សពួកសីហនុ ហើយនិងពួកយៀកមិញ កាប់ហែកស៊ីថ្លើមទាំងរស់នៅខេត្តកំពង់ចាម ។

នៅវេលារសៀលថ្ងៃទី១៩មីនា ប្រមាណជាម៉ោង៤, នៅក្នុងទីធ្លាក្រសួងឃោសនាការ, នៅក្នុងចំណោមមនុស្សច្រើនគ្នាដែលមានសេចក្តីតក់ស្លុត ព្រមទាំងមានទឹកមុខស្រពាប់ស្រពោនប្រហែលដូចជារូបខ្ញុំដែរ, ខ្ញុំមានវត្តមាននៅក្រោមដើមឈើមួយ ដែលមានឮរឧឃោសនស័ព្ទមួយយ៉ាងធំ ដើម្បីស្តាប់ការពន្យល់ជាលើកទី២របស់ឧត្តមសេនីយ៍-លន់-នល់ នាយករដ្ឋាភិបាល អំពីការទម្លាក់សម្តេចសីហនុ ។ តើនៅក្នុងពេលនោះ, នៅក្នុងចិត្តរបស់ខ្ញុំ, នៅក្នុងខួររបស់ខ្ញុំ មានសតិអារម្មណ៍ ឬក៏

មនោសញ្ចេតនាបែបណាដែរ ? ក្នុងមួយរំពេចនោះ ខ្ញុំមិនដឹងថា ខ្ញុំមានសេចក្ដីទន់ខ្សោយ ហាក់ដូចជាមានបាក់ទំនប់នៅពីខាងក្នុង ។ ខ្ញុំស្រាប់តែមានសេចក្ដីអាណិតអាសូរពន់ពេកចំពោះសម្ដេចសីហនុ ដែលបណ្ដាលឲ្យខ្ញុំស្រក់ទឹកភ្នែក ។ នេះជាលើកទី២ហើយក្នុងជីវិតរបស់ខ្ញុំ ដែលខ្ញុំស្ថិតនៅក្រោមទម្ងន់ទុក្ខព្រួយទប់ទឹកភ្នែកមិនបាន ដោយសារតែសម្ដេចសីហនុ ៖ កាលពីលើកទី១ គឺនៅក្នុងឆ្នាំ១៩៥៥ នៅពេលដែលព្រះអង្គដាក់រាជ្យ ។ ហើយកំរងអនុស្សាវរីយ៍បានហូរមក ដូចទឹកស្ទឹងទឹកទន្លេ គឺអនុស្សាវរីយ៍នៃអំពើល្អរបស់ទ្រង់ ជាពិសេសចំពោះខ្ញុំផ្ទាល់ ដែលតាមយាយីរូបខ្ញុំឥតត្រាប្រណី ។ តើជាអំពើអ្វីខ្លះទៅ ? ខ្ញុំនៅចាំបានថា ធ្លាប់មានយុវវ័យមួយ ដ៏សែនសុខសប្បាយនៅក្រោមការគ្រប់គ្រងរបស់ទ្រង់ ។ ខ្ញុំធ្លាប់មានមោទនភាពជាកូនខ្មែរ ក៏ដោយសារទ្រង់ដែរ ។ ក្នុងមួយរយ:ពេលដ៏យូរលង់ ទ្រង់ធ្លាប់មានលក្ខណ:ដូចជាឪពុកខ្ញុំបង្កើត ដែលខ្ញុំបានប្រគល់ជំនឿ, សេចក្ដីសង្ឃឹម និងសេចក្ដីស្រឡាញ់ដែលគ្មានបែងចែក ។ នៅពេលនោះទើបខ្ញុំដឹងថា ខ្ញុំក៏មានចិត្តពីរដូចឧត្តមសេនីយ៍លន់-នល់ដែរ គឺមិនច្បាស់លាស់, មិនដាច់ស្រេច, ស្ទាក់ស្ទើរ, ពោលនៅតែជាប់ចិត្តជានិច្ចជាកាលជាមួយនឹងស្ដេចអង្គនេះ ដែលជាជនផ្ដាច់ការមិនសមសក្ដិនឹងយើងសំរក់ទឹកភ្នែកទាល់តែសោះ, ព្រោះទ្រង់បានក្បត់ចិត្តយើងទាំងអស់គ្នាហើយបានបោះបង់យើងចោល ឲ្យធ្លាក់ចូលកណ្ដាប់ដៃខ្មាំងសត្រូវ ។ នៅជុំវិញខ្ញុំ មានពួកអ្នកខ្លះខ្សឹបខ្សៀវគ្នាសរសើរដម្កើងទ្រង់ ៖ «គុណាមួយរយសំពៅ ទោសមួយនៅរលាយបាត់អស់» , «សម្ដេចជាព្រះបិតាជាតិ, ជាវរជនស្នេហាជាតិ... គេមិនត្រូវវិនិច្ឆ័យទោសព្រះអង្គ ដោយគ្រាន់តែមានទោសកំហុសតែមួយប៉ុណ្ណោះទេ» ។

ខ្ញុំបើកឡាន Simca-Aronde របស់ខ្ញុំរត់គេចចេញពីទីនោះទៅ (ក្រសួងឃោសនាការ) ហាក់ដូចជារត់គេចចេញពីខ្លួនឯង ។ ខ្ញុំចេះតែកាច់ចង្កូតទៅដោយចៃដន្យមិនដឹងជាចង់ឆ្ពោះទៅទីណាទេ ។ ខ្ញុំឃើញឈ្មោះលោកចេង-ហេង ដែលត្រូវឡើងកាន់តំណែងជាប្រមុខរដ្ឋជំនួសស្ដេចសីហនុ... ជាឈ្មោះមួយដ៏គួរឲ្យធុញទ្រាន់ក្រៃពេក, ឈ្មោះដូចចិនស៊ីយិនគ្រុយ មិនសមរម្យមិនសមគួរនឹងតំណែងនេះទេ ។ បន្តិចក្រោយមក ខ្ញុំបានសំរេចចិត្តធ្វើដំណើរទៅចំការដូង ភូមិគំរូមួយរបស់លោកលន់-ណុន, ដោយមានសង្ឃឹមបែបយល់សប្ដិ ថានឹងបានជួបគាត់នៅទីនោះ ព្រមទាំងអាចស្ទាបស្ទង់ទឹកចិត្តរបស់លោកឧត្តមសេនីយ៍បងប្រុសរបស់គាត់ផងដែរ ។

មកដល់ពាក់កណ្ដាលផ្លូវ (ទំនងជាដល់ស្ទឹងមានជ័យ) រាត្រីក៏ធ្លាក់មកដល់ល្មម ។ ខ្ញុំស្ថិតនៅក្នុងផ្លូវដីហុយមួយអមដោយដើមត្នោត និងព្រៃគុម្ពោត ។ រំពេចនោះ ដោយសារភ្លើងឡានរបស់ខ្ញុំ ដែលចាំងទម្លុះស្បែងងងឹតដ៏ក្រាស់ឃ្មឹកបានមួយជុំធំ ខ្ញុំស្រាប់តែឃើញសត្វពស់មួយប៉ុនភ្លៅមនុស្ស ដែលរុំវេងជុំវិញខ្លួនវា សំរាប់ដេកនៅចំកណ្ដាលផ្លូវតែម្ដង ។ ខ្ញុំជាន់ហ្វ្រាំងឡានយ៉ាងគំហុក ។ មួយជាតិខ្ញុំនេះ ខ្ញុំភ័យខ្លាចសត្វពស់ណាស់ ទោះមានពិសក្ដី ទោះគ្មានពិសក្ដី ។ ខ្ញុំខំប្រឹងរវើកញ្ញក់ឡាន

ហើយចុចគន្លឹះសោដោយប្រុងប្រយ័ត្ន...។ ខ្ញុំឃើញសត្វពស់ដែលមានស្រកាភ្លឺផ្លេក នៅនឹងថ្នល់កន្លែងដដែល... វាទំនងដូចជាស្រវាំងភ្នែកនឹងភ្លើងឡានរបស់ខ្ញុំ ។ ខ្ញុំខំប្រឹងប្រមូលសេចក្តីក្លាហាន ដាក់លេខ១ ហើយជាន់ផ្ទឹបក្លាសកប់ជើង តំរង់ទៅរកសត្វពស់ (គឺហាក់ជាខ្ញុំតម្រង់ទៅបុកស្តេចសីហនុ) ។ ឮសម្លេងរលាក់...យឹក ! ដូចជាគួរសមដែរ... តែមិនគ្រប់គ្រាន់ទេ... ខ្ញុំទំនងជាបានកិនកន្ទុយពស់តែប៉ុណ្ណោះ ឬក៏បានប៉ះលើដុំថ្មអ្វីមួយផងក៏មិនដឹង ។ ខ្ញុំបត់ឡានមកក្រោយវិញជាប្រញាប់ ដើម្បីរកមើលសត្វពស់... ស្រាប់តែវាលូនចេញបាត់ពីទីនោះទៅហើយ ។ ខ្ញុំភិតភ័យតក់ស្លុតតក្កមា... «ប្រហែលជាវាលូនចូលក្នុងធុងឡានខាងក្រោយរបស់ខ្ញុំទេដឹង ??» ។ នៅក្នុងពេលជាមួយគ្នានោះ ខ្ញុំនឹកគិតថា ៖ «ប្រហែលជាស្តេចសីហនុត្រឡប់ចូលស្រុកខ្មែរវិញ តាមខេត្តសៀមរាបទេដឹង ?» ។

ខ្ញុំគ្មានសេចក្តីក្លាហាននឹងបន្តដំណើរទៅចំការដូងទេ ។ ខ្ញុំបកត្រឡប់មកផ្ទះរបស់ខ្ញុំវិញ ។ រឿងសត្វពស់ដែលខ្ញុំកិនមិនបាន ដោយសារតែគ្មានសេចក្តីសំរេចចិត្ត ធ្វើឲ្យសតិអារម្មណ៍ខ្ញុំទទួលការភ័ន្តភាំង ។ គឺវាហាក់ដូចជាថា លោកឧត្តមសេនិយលន់-នល់ និងពួកខាងរដ្ឋាភិបាលទាំងប៉ុន្មាន ព្រមទាំងរូបខ្ញុំផង យើងមិនអាចយកជ័យជំនះទៅលើស្តេចសីហនុបានទេ ។ ក៏ដូចតែសត្វពស់ដូច្នោះដែរ សម្តេចបានរត់គេចចេញរួចផុតទៅហើយ ។

❑

❑ ❑

នៅព្រឹកថ្ងៃទី២០មីនា១៩៧០, អ្នកនិពន្ធដ៏សំខាន់ពីររូបនៅក្នុងសារពត៌មាន«នគរធំ», លោកនួន-ឃឿន និងខាំម-ពូនគិមនី បានចូលមកជួបខ្ញុំនៅក្នុងការិយាល័យ ដើម្បីនិយាយប្រាប់ខ្ញុំថា... ពួកគេមិនអាចសហការនៅក្នុងកាសែតរបស់ខ្ញុំតទៅទៀតទេ ។ ពួកគេបាននិយាយដូចគ្នាថា នយោបាយរបស់ពួកគេ គឺ«ដើម្បីប្រឆាំងយួន មិនមែនដើម្បីទម្លាក់សម្តេចសីហនុទេ» ។ ក្នុងមួយរំពេជ ខ្ញុំស្រាប់តែអស់មិត្តភក្តិរលីង ។ លោកគីម-សែតនិពន្ធនាយក ក៏ត្រូវលោកជូ-ថានី តណ្តើមយកទៅបាត់ (លោកជូ-ថានីមានគោលជំហរគាំទ្រសម្តេចសីហនុ) ។

ដោយកំព្រាឯការឯកា ខ្ញុំក៏ខំប្រឹងស្ទាបស្ទង់អំពីប្រតិកម្មដំបូងនៃពួកអ្នកកាសែតបរទេស ជាពិសេសរបស់មនុស្សពីរនាក់ដែលមាននយោបាយប្រឆាំងគ្នា... ប៉ុន្តែដែលយោបល់មានសារៈសំខាន់ណាស់ចំពោះខ្ញុំ ៖ គឺលោក Bernard Hamel និងលោក Charles Meyer ។ ទាក់ទងនឹងលោក Bernard Hamel ខ្ញុំបានសួរគាត់ផ្ទាល់ (អំពីព្រឹត្តិការណ៍ទម្លាក់ស្តេច) នៅក្នុងឱកាសដែលខ្ញុំបានជួបគាត់មួយភ្លែតនៅក្រសួងឃោសនាការ ។ ចំពោះលោក Charles Meyer ខ្ញុំបានស្ទាបស្ទង់ជំរៅចិត្តតាមរយៈលោកអុំស៊ីម-វ៉ាវ ។ គឺវាហាក់ដូចជាថា អ្នកទាំងពីរមានគំនិតដូចគ្នា ដោយយល់ថា «លោកលន់-នល់មានថ្វីដៃអស្ចារ្យណាស់...ដោយបានធ្វើបដិវត្តន៍មួយ ដោយ

ឥតបង្ហូរឈាម» ។ តាមពិតលោក Charles Meyer ពិបាកស្ដាប់សួងណាស់ គាត់មិនសូវសំដែងមនោសញ្ចេតនាចេញមកខាងក្រៅទេ (ថ្ងៃក្រោយមកប្រវត្តិវិទូ David Chandler បានប្រាប់ខ្ញុំថា លោក Charles Meyer ជាភ្នាក់ងាររបស់រដ្ឋាភិបាលបារាំង ប៉ុន្តែនៅក្នុងព្រឹត្តិការណ៍១៨មីនា លោក Charles Meyer ដោយឥតលាក់លៀម បានជ្រើសរើសយកអ្នកអម្ចាស់ស៊ីសុវត្ថិ-ស៊ីរិមតៈ) ចំណែក Bernard Hamel វិញគាត់ជាមនុស្សសុទិដ្ឋិនិយម ហើយផ្អែកសេចក្ដីសង្ឃឹមត្រង់ៗទៅលើរដ្ឋាភិបាលលន់-នល់ ។ ចំណែកខ្លួនខ្ញុំវិញ ខ្ញុំដឹងពីជំរៅចិត្តខ្លួនឯងតែម្ដង... ថាស្ដេចសីសីហនុមិនងាយនឹងទទួលយកបរាជ័យរបស់ទ្រង់ទេ គឺទ្រង់ច្បាស់ជាធ្វើការសងសឹកមកលើពួកយើងវិញមិនខាន (បីបួនអាទិត្យក្រោយមក នៅពេលដែលទាហានខ្មែរទទួលការវាយប្រហារជាលើកដំបូងរបស់ជនជាតិយួន... នៅផ្ទះលោកស៊ឹម-វ៉ារ លោក Charles Meyer បានស្ដីបន្ទោសឲ្យខ្ញុំយ៉ាងធ្ងន់ធ្ងរបោរមុខថា ៖ «ពួកខ្មែរបានទៅច្បាំងនឹងពួកដែលមានកម្លាំងជាងពួកខ្លួន») ។

ចំណែកលោកអ៊ុំស៊ឹម-វ៉ារ, គាត់ក៏ដូចរូបខ្ញុំដែរ ត្រូវបាត់បង់សម្លេង និងគ្របសង្កត់ដោយព្រឹត្តិការណ៍ ។ តាំងពីដំបូងទីម្ល៉េះ... យើងទាំងពីរគ្រាន់តែមានអារម្មណ៍ភ័យខ្លាចស្ដេចសីហនុតែប៉ុណ្ណោះ ប៉ុន្តែយើងមិនបាននឹកស្មានជាមុន អំពីការដួលរលំរបស់ស្ដេច ដែលមានលំនាំដូចដីច្រាំងបាក់ធ្លាក់ទៅក្នុងទឹកទន្លេដូចនោះទេ ។ យើងក៏ហាក់ដូចជាមនុស្សពីរនាក់ ដែលរត់តាមមិនទាន់ព្រឹត្តិការណ៍ ។ បន្តិចក្រោយមកខ្ញុំបានដឹងថា លោកស៊ឹម-វ៉ារមិនព្រមទទួលដំណែងជាប្រធានក្រុមព្រឹទ្ធាចារ្យដើម្បីកាត់ទោសពួកសីហនុនិយមនោះទេ ។

នៅថ្ងៃក្រោយមក, ខ្ញុំបានដឹងតាមរយៈលោកលន់-ណុន ថានៅក្នុងថ្ងៃ២០មីនានោះ មានជន«ខ្មែរលើ»ចំនួន១៥នាក់បានចុះមកពីលើភ្នំកំពង់ស្ពឺ លីពូថៅនិងកាំបិតផ្គាក់គ្រប់ដៃ ដើម្បីមកសួរឧត្ដមសេនីយ៍លន់-នល់ពីការទម្លាក់សម្ដេចសីហនុ ។ បន្ទាប់ពីឧត្ដមសេនីយ៍លន់-នល់បានបញ្ជាក់ពីសមានចិត្តស្មោះត្រង់របស់លោក ក៏ស្រាប់តែពួកទាំងនេះវិលត្រឡប់ទៅវិញបាត់អស់ទៅ ។ តើលោកឧត្ដមសេនីយ៍បាននិយាយយ៉ាងណាខ្លះដែរ បានជាពួកជនព្រៃភ្នំទាំងអស់នេះ ទទួលយល់ព្រមដោយងាយស្រួលម្ល៉េះ ? ប្រហែលជាលោកបាននិយាយថា រូបលោកហើយនិងសម្ដេចសីហនុ បានចែកផ្លូវគ្នាដើរ ដើម្បីរកមធ្យោបាយផ្សេងគ្នា ជួយឲ្យកម្ពុជាបានចំរុងចំរើន ? ។ ទោះជាយ៉ាងណាក្ដី ពាក្យចចាមអារាមបែបដូចនេះ កំពុងតែហោះហើរសោត់អណ្ដែតផ្សព្វផ្សាយពាសពេញរដ្ឋធានី ដោយបណ្ដាលឲ្យប្រជាជន មានការភ័ន្តភាំងស្រឡាំងកាំងស្មារតី ។

❑

❑ ❑

ខ្ញុំបានត្រូវលោកលន់-ណុនកោះហៅនៅព្រឹកថ្ងៃទី២១មីនា ។ ខ្ញុំបានជួបមិត្តភក្តិ

របស់ខ្ញុំ ថោង-លឹមហួង នៅទីនោះផងដែរ ។ លោកលន់-ណុនចង់ឲ្យខ្ញុំកាន់កាប់ទីភ្នាក់ងារពត៌មានខ្មែរ ដើម្បីត្រួតពិនិត្យមើលក្រសួងឃោសនាការ... ដោយខ្ញុំមិនស្រឡាញ់កិច្ចការនេះ ខ្ញុំក៏បង្វែទៅឲ្យលោក ថោង-លឹមហួង វិញ (ដូច្នេះទង្វើលន់-នល់, លន់-ណុន ក្នុងរដ្ឋប្រហារនេះ... គ្រាន់តែដាក់មនុស្សកំប៉ិកកំប៉ុកម្នាក់ឲ្យទៅកាន់កាប់អាកាប៉េ... ក្រៅពីនេះគឺជាកិច្ចការរបស់ទ្រង់សិរិមតៈទាំងអស់ ដែលជារដ្ឋមន្ត្រីទី១-ទី២) ។

លោកលន់-ណុនបានប្រាប់យើងទាំងពីរនាក់ថា លោកឧត្តមសេនីយ៍លន់-នល់ចង់ចោទសំនួរមួយដ៏សំខាន់ទៅកាន់ពួកក្មេងៗ (ជាពិសេសមកកាន់ខ្ញុំ ហើយនិងថោង-លឹមហួង) ៖ «តើគេត្រូវធ្វើយ៉ាងណាដែរ ចំពោះពួកសីហនុនិយម ?» ។

ថោង-លឹមហួងមិនបាននិយាយស្តីអ្វីមួយម៉ាត់ ។ ចំណែកខ្ញុំវិញបានបួលឆ្លើយបល់ថា គួរតែចាប់ពួកសីហនុដាក់មួយកន្លែង ដើម្បីឃ្លាំមើលពួកគេ ដើម្បីកុំឲ្យពួកគេធ្វើបរបដិវត្តន៍ (contre-révolution) ។ លោកលន់-នល់បានបញ្ជូនចម្លើយរបស់គាត់តបមកខ្ញុំវិញនៅថ្ងៃស្អែកមួយទៀត ៖ «បើយើងហើយគ្រប់គ្រងតាមរបៀបសក្តិភូមិរបស់សម្តេចសីហនុដដែល តើគេចាំបាច់ត្រូវការអ្វីទៅទម្លាក់ព្រះអង្គ ?» ។ លោកលន់-នល់បានបញ្ជាក់បន្ថែមទៀតថា លោកមិនចូលចិត្តបដិវត្តន៍បារាំងទាល់តែសោះ ដែលពួកមេដឹកនាំបានប្រហារគ្នាឯងគ្មានសល់ ដូចជា Robespierre បានប្រហារ Danton ។ល។ និង ។ល។ (លោកលន់-នល់បានបញ្ជាឲ្យគេដោះលែងនងសួន ហើយនិងភោគ-ឆាយ ម្នាក់ជាមេខ្មែរយៀកមិញ... ម្នាក់ជាមេខ្មែរក្រហម) ។ នៅពេលវឹកវរចលាចល លោកនឹងបញ្ជាឲ្យចាប់ពួកសីហនុនិយមមួយក្តាប់តូចមានអ៊ុម-ម៉ាណូរិន, សុស្តែន-ហ្វែរណង់ដែស, ប៊ូ-ហ៊ល, អ៊ឹង-ហុងសាធ, ទេព-ឈីវខេង ដើម្បីគ្រាន់តែជានាមប៉ុណ្ណោះ ដើម្បីគ្រាន់តែដោះលែងពួកទាំងនេះទៅវិញជាបន្ទាប់មក ។ ជាសេចក្តីអភ័ព្វរបស់លោក ហើយនិងជាសំណាងអាក្រក់របស់សាធារណរដ្ឋខ្មែរ ដែលថ្ងៃមុខទៅលោកគ្រប់គ្រងជាប្រធានាធិបតី លោកលន់-នល់នឹងតែងតាំងសុស្តែន-ហ្វែរណង់ដែស មនុស្សដៃជើងម្នាក់របស់ស្តេចសីហនុ ឲ្យធ្វើជានាយសេនាធិការ និងជាអគ្គមេបញ្ជាការកងយោធា សឹងតែពេញមួយរយៈកាលនៃសាធារណរដ្ឋខ្មែរ ។

នៅថ្ងៃនោះ (ទី២១មីនា) មានមនុស្សច្រើនណាស់នៅផ្ទះលោកលន់-ណុន គឺមានពួកមេទាហានលន់-នល់និយម ៖ ឡេស-កាសេម, ថាច់-ប៉ូច, ថាច់-រ៉េង និងពួកជនដែលថ្ងៃមុខទៅក្លាយទៅជាពួកគ្រូឧប្បជ្ឈាយ៍នៃសាធារណរដ្ឋ ៖ កេង-វ៉ាន់សាក់, ភួង-តុន, ហង្ស-ធុនហាក់ ពួកគេជាជនឥតវិញ្ញាណ (inconscients) ដែលនាំគ្នាត្រេកអរសប្បាយប្រហែលគ្នានឹងមនុស្សដែលរាំរែកក្នុងរាត្រីសមោសរ ។ ពួកគេមិនដឹងទេថា ការសប្បាយរបស់ពួកគេមានរយៈពេលខ្លីពេកណាស់ ដែលពួកយួនដែលប្រដាប់ដោយគ្រឿងអាវុធស្រោចខ្លួន បានឡោមព័ទ្ធពួកគេជុំជិតអស់ទៅហើ-

យ ជុំវិញទីជំរកដ៏គួរឲ្យចង់សើចរបស់ពួកគេ ។ ដោយមានការប្រទានពរពីស្តេចសីហនុ... ពួកជនកុម្មុយនិស្តនឹងធ្វើការច្រូតកាត់ពួកគេមួយម្តងៗ... ប្រហែលគ្នានឹងគេច្រូតស្មៅ ។៚

❑ ❑

❑